**រាជបណ្ឌិត្យសភាកម្ពុជា**

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## ភាគទី៧ - វគ្គទី៤

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា




អ្នកទៅចូលរួមក្នុងពិធីសម្ពោធ «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»[1]

[1] **https://i.pinimg.com/originals/fe/53/31**

នៅក្នុងភាគទី៧ វគ្គទី៤ ដែលជាវគ្គបញ្ចប់នៃសុន្ទរកថារបស់លោករេស៊ីដង់ជាន់ខ្ពស់បារាំងនេះ យើងសូមលើកយកបណ្ណសារស្ដីពី «បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨)»[2] មកបង្ហាញបន្ត ដោយមានខ្លឹមសារដើម និងមានការកែសម្រួលមួយចំនួនដូចខាងក្រោម៖

នគរបារាំងសែស បានចាត់ចែងឱ្យរៀបរយ ពុំមែនរៀបរយដោយសង្កត់សង្កិនបង្ខំទេ គឺរៀបរយដោយចិត្តប្រាថ្នានៃបណ្ដារាស្រ្ត ដែលចង់ធ្វើការរកស៊ីដោយសុខក្សេមក្សាន្ត ហើយឱ្យបានផលប្រយោជន៍មកប្រើការ។

ឯនគរក្រុងកម្ពុជា ដែលបាក់បែកខូចខាតដោយមានចម្បាំងរាំងដល់មកពីប្រទេសក្រៅ ឬកើតនៅក្នុងស្រុកនោះ នគរបារាំងសែសបានដឹកនាំ និងជួយទំនុកបម្រុងឱ្យកើតឡើងជានគរ១បរិបូណ៌ មានផ្លូវធំទូលាយគ្រប់ទិស ដើរបានដោយស្រួល ឥតមានភ័យបារម្ភអ្វីឡើយ។ គ្មានច្បាំងចេញមួយដំណាក់ឈាមនោះនគរបារាំងសែសបានយកខេត្ត ដែលសត្រូវដណ្តើមទៅ មកប្រគល់ឱ្យនគរក្រុងកម្ពុជាវិញ។ នគរបារាំងសែសបានផ្ចាញ់ផ្ចាលជាមាំមួនតាមបេត់របៀបជំងឺ ដែលកាលពីដើមនាំឱ្យខូចខាតមនុស្សជាច្រើន ហើយដែលឥឡូវនេះកាន់តែអន់ៗតែរាល់ថ្ងៃ[3]។ នគរបារាំងសែស បានផ្សាយការរៀនសូត្រហើយបានសាងវត្តឡើងវិញ វត្តដែលជាទីកន្លែងបណ្ដារាស្រ្តខ្មែរប្រជុំតាមផ្លូវសាសនាខ្មែរ។ នគរបារាំងសែសមិនមែនគិតចង់បំផ្លាញសេចក្តីដែលបណ្ដារាស្រ្តខ្មែរជាន់ឥឡូវនេះនឹករំឭកដល់កាលបុរាណរបស់ខ្លួន ដែលថ្កុំថ្កើងរុងរឿងដើម្បីនឹងគេស្និទ្ធស្នេហានឹងខ្លួននោះទេ[4] មានតែខិតខំធ្វើឱ្យសាវតារបុរាណនោះ លេចឡើងឱ្យឃើញច្បាស់ថែមទៀត។ នគរបារាំងសែស ខិតខំថែរក្សាប្រាសាទបុរាណទាំងប៉ុន្មាន ដែលគេសរសើរនៅគ្រប់ប្រទេសក្នុងជម្ពូទ្វីប ហើយដែលជាទីញ៉ាំងគោលចារឹកថ្វីដៃ និងចំណេះខាងចម្បាំង របស់ជនជាតិខ្មែរ ហើយនិងសេចក្តីឧត្តមប្រសើរ នៃសាវតារជានគរក្រុងកម្ពុជាធិបតី។ នគរបារាំងសែស ទុកឱ្យនៅមានទំនុំទំនៀមខាងផ្នែកសាសនា បានឱ្យរៀនសូត្រភាសាបាលី សំស្ក្រឹត ហើយបានរៀបចំការរចនា ដែល

---

[2] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥ ទំព័រ៩០-៩៥។

[3] ឃ្លានេះមានន័យថា ប្រទេសបារាំងមានជោគជ័យក្នុងការកម្ចាត់ជំងឺនានា ដែលនាំឱ្យស្លាប់មនុស្សជាច្រើននៅសម័យនោះ ដូចជា៖ ជំងឺពិស ជំងឺអុតធំ និងជំងឺអាសន្នរោគ (la peste, la variole et le choléra)។

[4] ឃ្លានេះមានន័យថា បារាំងមិនបានហាមឃាត់ខ្មែរចំពោះការរំឭកអំពីភាពរុងរឿងនៃអតីតកាលរបស់ខ្មែរនោះទេ។

ហៀបនឹង[5]រលត់សោះសូន្យ។ រាជការអាណាព្យាបាលគ្មានធ្វើការអ្វីឱ្យចិត្តគំនិតបណ្ដារាស្ត្រខ្មែរ កែប្រែទៅតាមបទអាក្រក់ទេ មិនតែប៉ុណ្ណោះបានប្រុងប្រយ័ត្នជាមាំមួន មិនឱ្យបទអាក្រក់បៀតបៀនខ្លួនបណ្ដារាស្ត្រខ្មែរ ប្រៀបដូចជាបានធ្វើការកាប់គាស់ដើមឈើ ដែលដុះរុំប្រាសាទបុរាណនោះចេញអស់[6]។ ការដែលបានធ្វើដូច្នេះទៅទើបចំណេះដឹងដ៏ប្រសើរនៃបណ្ដារាស្ត្រខ្មែរលេចចេញភ្លឺច្បាស់ក្នុងគ្រាឥឡូវនេះ ហើយដែលបានលទ្ធផលដូច្នេះនេះ គឺដោយសារមាននគរបារាំងសែសជួយផង។ ឯទំនាយបុរាណដែលចងទុកមកថា នគរក្រុងកម្ពុជាធិបតីមិនសោះសូន្យទេនោះ ឃើញច្បាស់ជាប្រាកដថា នគរក្រុងកម្ពុជាប្រាកដជាមិនសោះសូន្យមែន។

ដោយសារអាយុជីវិតនៃនគរនេះផ្សារភ្ជាប់ជាជរាបជាមួយនឹងអាយុជីវិតនៃនគរបារាំងសែសនោះ អ្នកដែលបានបាត់បង់ជីវិតទៅក៏បានយល់ច្បាស់ហើយ ទើបអ្នកទាំងនោះហ៊ានទៅតទល់នឹងគ្រឿងអាវុធសម្បើមជាទីបំផុត របស់អ្នកដែលប្រព្រឹត្តបទទុច្ចរិត(ប្រទេសអាល្លឺម៉ង់)។ ទោះបីជាអ្នកយល់ពុំបានភ្លឺច្បាស់ក៏ដោយ ក៏គង់តែអ្នកដឹងក្នុងពោះថា បើទ័ពអាល្លឺម៉ង់ចូលក្នុងដែនបារាំងសែសបានជោគជ័យនោះ ជីវិតអ្នកឯងនិងទ្រព្យរបស់ញាតិសន្ដាន ផ្នូរជីដូនជីតានិងព្រលឹងអ្នកឯងមុខជារងគ្រោះ ក្នុងពេលនោះជាមិនខានឡើយ។ ហើយដែលអ្នកទៅបង់ជីវិតជួយនគរបារាំងសែសនោះ ទុកដូចជាអ្នកជួយនគរក្រុងកម្ពុជាផងដែរ។

អ្នកបានទៅធ្វើការឱ្យព្រះមហានគរ និងឱ្យស្រុកអ្នកក្នុងវេលាចម្បាំងគ្មានគិតវែងឆ្ងាយអ្វី អ្នកទៅនោះដូចគេតទល់នឹងចោរកំណាចនិងបក្សាអាក្រក់។ អ្នកដែលទៅដោយសេចក្ដីសុចរិត ដែលអ្នកកាន់ពីជីដូនជីតាមក ដោយសេចក្ដីក្លាហាន ដូចអ្នកមានថ្វីដៃពីបុរាណហើយ ដោយមានសេចក្ដីសង្ឃឹមថាខ្មោចអ្នកនោះ គេតម្កល់តម្កើងច្រើនពាន់ឆ្នាំទៅមុខ។

ឥឡូវនេះខ្ញុំបែរមកខាងអ្នកឯងរាល់គ្នា ដែលជាកូនសិស្សរៀនសូត្រនៅសាលាយើង។ អ្នកឯងក្នុងថ្ងៃនេះមានសេចក្ដីរំជួលជាមួយគ្នាទាំងអស់ទុកជាសាសន៍ដទៃពីគ្នាក៏ដោយ។ អ្នកឯងនៅក្នុងកំឡុងអាយុដែលសេចក្ដីស្រៀវស្រើប នៅជាប់ខ្លាំងក្នុងគំនិតចិត្តអ្នកឯង ចិត្តខ្ញុំចង់ឱ្យឱកាសបុណ្យនេះនាំគំនិត

---

[5] ហៀបនឹង គឺទៀបនឹង ជិតនឹង រកកល់នឹង វចនានុក្រម ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ទំព័រ១៥២៨។

[6] ឃ្លានេះមានន័យថា បារាំងបានជួយសម្អាតចិត្តខ្មែរប្រៀបដូចជាការសម្អាតប្រាសាទបុរាណ ដែលមានព្រៃព្រឹក្សាដុះព័ទ្ធជុំជិត ជាពិសេសក្រោយពេលសៀមប្រគល់ខេត្តបាត់ដំបង សៀមរាប និង សិរីសោភ័ណ្ឌ នៅឆ្នាំ១៩០៧។ សកម្មភាពសម្អាតប្រាសាទនេះ បានធ្វើពីឆ្នាំ១៩០៨ ដល់ ឆ្នាំ១៩៣០ ក្នុងក្របខណ្ឌនៃ«កិច្ចអភិរក្សអង្គរ» (Conservation d’Angkor)។

មារយាទអ្នកឯងឱ្យសម្រេចទៅតាមផ្លូវមួយជាស្រេច តាំងពីថ្ងៃនេះតទៅ។ ខ្ញុំចង់ឱ្យឱកាសបុណ្យនេះនៅក្នុងគំនិតមារយាទអ្នកទាំងស្រុង ប្រៀបដូចវិមាននេះ នៅកណ្ដាលទីនេះឯង។

ឯបារាំងសែសនិងខ្មែរ ដែលស៊ូប្រថុយជីវិតស្លាប់បង់នេះ គឺដើម្បីឱ្យអ្នកឯងរាល់គ្នា បានរស់នៅដោយឯកចិត្ត ហើយកុំឱ្យអាប់ឱនកិត្តិយស។ ឯខ្លួនអ្នកឯងមិនមែនគ្រាន់តែឱនក្បាលគោរពប្រណិបត្តិនៅមុខវិមាន ដែលមានកត់ឈ្មោះអ្នកទាំងនោះ ហើយគ្រាន់តែនឹករំឭកដល់តែប៉ុណ្ណោះទេ គឺត្រូវធ្វើជាបន្តនិងបង្ហើយកិច្ចការដែលអ្នកទាំងនោះបានចាប់ផ្ដើមធ្វើកន្លងមក។

អើ!យើងប្រាថ្នា យើងសង្ឃឹមឱ្យអ្នករាល់គ្នាជៀសរួចផុតពីសេចក្ដីទុក្ខ ដែលអ្នកទាំងនោះទៅទ្រាំត្រដរបង់ជីវិត ឯការសឹកសង្គ្រាមនេះបង្កើតបទល្អប្រសើរប្រាកដមែន តែទម្រាំបានបទល្អនោះមក ត្រូវប្ដូរថ្លៃណាស់ បានហៅថាពេញជាមនុស្ស។ ប៉ុន្តែពេលនឹកដល់រឿងនេះ មានសេចក្ដីស្អប់ខ្លាំង។ ១ទៀតអ្នកទាំងនោះស៊ូស្លាប់បង់ជីវិតនេះ ដើម្បីឱ្យអ្នករាល់គ្នាបានសេចក្ដីសុខ តែសេចក្ដីសុខនោះត្រូវឱ្យមានធ្វើការឱ្យបានផលប្រយោជន៍។ តែអ្នកឯងរាល់គ្នាបណ្ដែតបណ្ដោយពុំធ្វើនៅក្នុងវេលាដែលខ្លួននៅក្មេងនេះ ទុកជាអ្នកឯងក្បត់អ្នកទាំងនោះ។ នៅជុំវិញខ្លួនអ្នកឯង មាននគរ១ធំ ដែលមានផ្ទៃដីទូលំទូលាយ ផ្ដល់ផលច្រើនឥតគណនា។ អ្នកឯងត្រូវខិតខំស៊ូអត់ទ្រាំនិងឱ្យមានចិត្តជឿជាក់ពីការងារអ្នកឯងធ្វើ ដើម្បីនឹងយកផលចេញពីដីនោះ ដោយបានកាន់សេចក្ដីទាំងនេះ ទើបអ្នកទៅច្បាំងឈ្នះគេបាន។ មួយទៀតត្រូវចាំទុកជាដរាបដូចជារបស់ដែលគេគោរពប្រណិបត្តិសេចក្ដីរួមចិត្តចូលគ្នា ដូចបងប្អូនបង្កើតនិងសេចក្ដីជួយគ្នាទៅវិញទៅមក ដែលអ្នកទាំងនោះបានយកឈាមទៅចងភ្ជាប់។

ប៉ុន្តែខ្ញុំមានសេចក្ដីអំណរជឿជាប្រាកដ ថាពាក្យទូន្មានប្រដៅនេះ ទុកជាលើសហួសឥតប្រយោជន៍ក៏បាន។ នៅលើវិមានថ្មកែវនេះកូនក្មេងដែលម្ដាយមានសេចក្ដីអរខ្លាំង ហុចទៅឱ្យអ្នកដែលមានជ័យជម្នះនេះសមជាកូនចៅសាសន៍មនុស្សចិត្តក្លាហានជាប្រាកដ។

ឱអ្នកមរណៈបារាំងសែស! អ្នកមរណៈខ្មែរ! ដែលឈាមលាយចូលគ្នា ក្នុងវេលាចម្បាំងនាំបណ្ដាលឱ្យនគរអាណាព្យាបាល និងនគរដែលនៅក្នុងបន្ទុកនគរនោះជាប់ស្ពានមេត្រីគ្នាតាំងពីឥឡូវនេះទៅនិងឃ្លាតពីគ្នាពុំបាន។ ឱខ្មោចដែលយើងគោរពប្រណិបត្តិ! ដោយយើងមានសេចក្ដីកោតសរសើរ និងសេចក្ដីកតញ្ញូព្រមគ្នានោះ អ្នករាល់គ្នាបានទៅច្បាំងហើយអនិច្ចកម្មទៅ យើងបន់សុំឱ្យចម្បាំងដែលធំគួរស្ញែងដែលអ្នកបានចូលតយុទ្ធនេះជាចម្បាំងក្រោយបង្អស់ កុំឱ្យមានតទៅទៀត។ អ្នកផ្សាយឈាមអ្នកចេញគ្មានគិត អ្នកស៊ូបង់ជីវិតបំណងឱ្យតែស្រុកជូនតាអ្នកមកក្រោយមក បានសុខសាន្តត្រាណជាយូរអង្វែង ដើម្បីឱ្

យមានកម្លាំងឡើងវិញ ហើយនឹងបានជួសជុលរបស់បាក់បែកខូចខាតជាច្រើន ក្នុងវេលាចម្បាំងធំជាទីបំផុតនេះ។

ឯបទល្អប្រសើរ នូវសេចក្តីដែលអ្នកស៊ូបង់ជីវិតនេះ នៅជាដរាបក្នុងពោះយើង។ សូមឱ្យអ្នកមានសេចក្តីថ្កុំថ្កើងរុងរឿង។

ឯឈ្មោះអ្នកកត់ជាប់នៅៗ ក្នុងចិត្តគំនិតសាសន៍ទាំង២នេះ។

ឯទង់ជ័យមានជ័យជម្នះរបស់យើងនេះ ក៏ឱនប្រណិបត្តិអ្នករាល់គ្នា។ សូមឱ្យអ្នកបានមគ្គផលកុសលបុណ្យដោយសេចក្តីល្អ ដែលអ្នកបានធ្វើទុកនូវគំរូដែលអ្នកកត់ក្នុងថ្មកែវ និងសំរឹទ្ធិនេះទុកជាដរាបឱ្យអ្នកឯក្រោយយកតម្រាប់តាម។ ខ្លួនអ្នកប្រៀបដូចជាគោម ដែលក្នុងវេលាក្រីក្រនោះ កូនចៅជាន់ក្រោយនឹងបែរក្រឡេកមកមើលជាដរាប។ ខ្លួនអ្នកប្រៀបដូចជាភ្លើងដែលគំនិតមាតាកាលណាអន់ទន់(ចង់រលត់) នឹងមកអុជឱ្យមានកម្លាំងឡើងវិញ ហើយភ្លើងនោះបណ្តាលនាំឱ្យមានសេចក្តីល្អក្នុងព្រះនគរគ្មានអាក់ព្រោះភ្លើងនោះសម្លាប់បទទុច្ចរិតអាក្រក់។

(សូមរង់ចាំអានភាគបន្ត...)